ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការកំណត់ចំណូលពីសោហ៊ុយសេវាសុរិយោដី

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ៣៧៧ សហវ

រាជធានីភ្នំពេញ.ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០២

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការកំណត់ចំណូលពីសោហ៊ុយសេវាសុរិយោដី
# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
# រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- អនុវត្តតាមអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួត

ពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វ័យតរាជធានីភ្នំពេញ និងអង្គការសាធារណរដ្ឋបាល

- អនុវត្តតាមអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- អនុវត្តតាមប្រកាសលេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ
- អនុវត្តតាមសារាចរណែនាំលេខ ០០២ សហវ.ម ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីរជ្ជទេយ្យ ចំណូល
- តាមការចាំបាច់ក្នុងការអនុវត្តន៍ច្បាប់ភូមិបាល

**សំរេច**

**ប្រការ ១.-**

អនុញ្ញាតអោយយកសោហ៊ុយសេវាសុរិយោដីលើការចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ការចេញប័ណ្ណទុតិយតា ការចេញប័ណ្ណតតិយតា ការផ្ទេរសិទ្ធិលើអចលនវត្ថុ ការចេញលិខិតបញ្ជាក់សុរិយោដី (ហ៊ីប៉ូតែក បញ្ចាំ ដាក់ធានា) ការចេញសាលាកប័ត្រព័តិមាន ការចេញលិខិតបញ្ជាក់សុរិយោដី និងការថតចំលងឯកសារ ព្រមទាំងការបំពេញបែបបទ ឯកសារផ្សេងៗទៀតដែលទាក់ទង និងការងារ សុរិយោដី ។

**ប្រការ ២.-**

សោហ៊ុយសេវាសុរិយោដី ត្រូវបានកំណត់ដូចតទៅ :

| ល.រ | បរិយាយ | សោហ៊ុយសេវាសុរិយោដី | | |
|---|---|---|---|---|
| | | ដីផលិតកម្ម ឬដីភោគ | ដីលំនៅដ្ឋាន និងដីសំរាប់សំណង់ទូទៅ | |
| | | | ជនបទ ឬក្រៅក្រុង | ទីក្រុង ឬទីរួមខេត្ត |
| ១ | ការចេញប័ណ្ណ ឬប័ណ្ណទុតិយតា ឬប័ណ្ណតតិយតា"ក្នុង១ក្បាលដី" | ៥.០០០៛០០ | ១០០.០០០៛០០ | ៣៥០.០០០៛០០ |
| ២ | ការផ្ទេរអចលនវត្ថុ (ផ្ទេរដោយបំបែក ឬផ្ទេរទាំងមូល) "ក្នុង១ ប័ណ្ណ" | ៥០.០០០៛០០ | ៨០.០០០៛០០ | ១០០.០០០៛០០ |
| ៣ | ការបង្រួមក្បាលដី"ក្នុង១ក្បាលដី" | ១០០.០០០៛០០ | ១២០.០០០៛០០ | ១៥០.០០០៛០០ |
| ៤ | ការចេញលិខិតបញ្ជាក់(ហ៊ីប៉ូតែក ដាក់បញ្ចាំ ដាក់ធានា) ក្នុង១ក្បាលដី | ១៥.០០០៛០០ | ១៨.០០០៛០០ | ២០.០០០៛០០ |
| ៥ | ការចេញសាលាកប័ត្រពតិមាន "ក្នុង ១ក្បាលដី" | ១៥.០០០៛០០ | ១៨.០០០៛០០ | ២០.០០០៛០០ |
| ៦ | ការចេញលិខិតបញ្ជាក់សុរិយោដី ក្នុង | ១៥.០០០៛០០ | ១៨.០០០៛០០ | ២០.០០០៛០០ |

| | | | | |
|---|---|---|---|---|
| | ១ក្បាលដី | | | |

ចំពោះការផ្ទេរសិទ្ធិលើអចលនវត្ថុ សោហ៊ុយសេវាសុរិយោដីជាបន្ទុករបស់អ្នកទទួលសិទ្ធិ

អ្នកទទួលសិទ្ធិអចលវត្ថុក៏ត្រូវបង់ពន្ធផ្សេងៗទៀតតាមច្បាប់សារពើពន្ធជាធរមាន ។

**ប្រការ ៣.-**

សោហ៊ុយសេវាសុរិយោដីលើការវាស់វែងដីដោយប្រើឧបករណ៍វាស់ស្ទង់ទំនើបត្រូវបានកំណត់ដូចខាងក្រោម

| **ល.រ** | **បរិយាយ** | **<u>សោហ៊ុយក្នុង១ហិកតា</u>** |
|---|---|---|
| ១ | ទំហំដីតិចជាង ១០ ហិកតា | ៣០.០០០៛០០ |
| ២ | ទំហំដីចាប់ពី ១០ ហិកតា ដល់ ៥០ហិកតា | ១៥.០០០៛០០ |
| ៣ | ទំហំដីចាប់ពី ៥១ ហិកតា ដល់ ៣០០ហិកតា | ១០.០០០៛០០ |
| ៤ | ទំហំដីចាប់ពី ៣០១ ហិកតា ដល់ ១.០០០ ហិកតា | ៨.០០០៛០០ |
| ៥ | ទំហំដីចាប់ពី ១.០០០ ហិកតាឡើងទៅ | ៦.០០០៛០០ |

ចំពោះដីដែលមានទីតាំងឆ្ងាយលើសពី ៥០ គីឡូម៉ែត្រពីអង្គភាពសុរិយោដីម្ចាស់ដីត្រូវទទួលបន្ទុកបន្ថែមលើ :

១-សោហ៊ុយធ្វើដំណើរ ស្នាក់នៅ ហូបចុក របស់មន្ត្រីជំនាញ ។

២-ថ្លៃបង្គោល និងការដាំបង្គោលព្រំ ។

៣-ចំពោះតំបន់ព្រៃភ្នំ សោហ៊ុយសេវាសុរិយោដីត្រូវគិតបន្ថែម ២០% លើសោហ៊ុយសេវាវាស់វែងសរុប ។

**ប្រការ ៤.-**

រាល់ទំរង់បែបបទឯកសារសុរិយោដីដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តតាមនីតិវិធីសុរិយោដី ។

**ប្រការ ៥.-**

-ការបង់ប្រាក់ និងការទទួលប្រាក់ចំណូលពីសោហ៊ុយសេវាសុរិយោដី ត្រូវអនុវត្តតាមរយៈរជ្ជទេយ្យករចំណូល នៅថ្នាក់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ។

-ក្នុងករណីចាំបាច់អាចបង្កើតរជ្ជទេយ្យករចំណូលរង នៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខ័ណ្ឌ ។

-ការបោះពុម្ព និងការបើកផ្តល់ប័ណ្ណចំណូលពីសោហ៊ុយសេវាសុរិយោដីជាបន្ទុករបស់ថវិការដ្ឋដែលចាត់ចែងអនុវត្តដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**ប្រការ ៦.-**

ការគ្រប់គ្រងចំណូលពីសោហ៊ុយសេវាសុរិយោដី ត្រូវអនុវត្តតាមនីតិវិធីនៃកិច្ចប្រតិបត្តិការថវិកាទូទៅរបស់

រដ្ឋ ។

**ប្រការ ៧.-**

ចំណូលពីសោហ៊ុយសេវាសុរិយោដី ត្រូវបានកំណត់បែងចែកដូចខាងក្រោម :

១- ៧៥% សំរាប់បង់ចូលថវិការដ្ឋក្នុងនោះមាន ៣៥% ដែលជាចំណែករបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សំរាប់ចាត់ចែងចំណាយដល់អង្គភាពជំនាញសុរិយោដីក្រោមឱវាទ ។

២- ១៥% សំរាប់បំរើឱ្យគុណប្រយោជន៍ថវិការបស់ខេត្ត ក្រុងក្នុងនោះមាន ៥% ដែលជាចំណែករបស់ស្រុក ខ័ណ្ឌ ។

៣-១០% សំរាប់បំរើឱ្យគុណប្រយោជន៍ថវិការបស់ឃុំ សង្កាត់ ។

**ប្រការ ៨.-**

ចំណូលពីសោហ៊ុយសេវាសុរិយោដីត្រូវបង់ចូលថវិការដ្ឋ និងថវិកាខេត្ត ក្រុងនៅរតនាគារខេត្ត ក្រុងដោយកត់ត្រានៅក្នុងជំពូក២១ ប្រការ ០៣ កថាខ័ណ្ឌ ១៩ ។ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ត្រូវបូកសរុបធ្វើរបាយការណ៍នៃចំណូលនេះ ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុង១ត្រីមាសម្តង ដោយភ្ជាប់មកជាមួយនូវសាលាកប័ត្របង់ប្រាក់ ។

**ប្រការ ៩.-**

ផ្អែកលើការបូកសរុបសភាពការណ៍បង់ចំណូលប្រចាំត្រីមាសដូចមានចែងនៅក្នុងប្រការ៨ ខាងលើ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវលើកសំណើសុំចំណាយក្នុងរង្វង់ ៣៥%នៃចំណូលដែលបានបង់ចូលថវិការដ្ឋមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យសម្រេចផ្តល់ជូនតាមចំណែកដែលត្រូវបានទទួលជូនវិញ តែត្រូវភ្ជាប់មកជាមួយនូវ :

- សាលាកប័ត្របង់ប្រាក់ចំណូលពីសោហ៊ុយសេវាសុរិយោដី
- របាយការណ៍ចំណាយនៃចំណែក ៣៥%ដែលថវិការដ្ឋបានបើកផ្តល់លើកមុនដោយមានភ្ជាប់មកជាមួយនូវសក្ខីប័ត្រគ្រប់គ្រាន់ និងត្រឹមត្រូវ ។

នីតិវិធីនៃការបើកផ្តល់ចំណាយ ត្រូវធ្វើឡើងតាមរយៈអាណត្តិបើកប្រាក់ ដោយកត់ត្រានៅក្នុងជំពូក ១១.០១ ១៤.០២ ។

**ប្រការ ១០.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ១១.-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានថវិកានីយកម្ម និងហិរញ្ញកិច្ច ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ប្រធានរតនាគារជាតិ អង្គភាពពាក់ព័ន្ធទាំងអស់ដែលស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែន នគរូបនីយកម្ម និងសំណង់មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះ ។

**ប្រការ ១២.-**

ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **ទេសរដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
| **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | **ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** |
| **ហត្ថលេខា និងត្រា** | **ហត្ថលេខា និងត្រា** |
| **គាត ឈន់** | **អ៊ឹម ឈុនលឹម** |

<u>កន្លែងទទួល</u>

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អាជ្ញាធរសវនកម្មជាតិ

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន

-គ្រប់សាលាខេត្ត ក្រុង "ដើម្បីជូនជ្រាប"

-ដូចប្រការ១១"ដើម្បីអនុវត្ត"

-ឯកសារ និងកាលប្បវត្តិ